# Presumptive Eligibility សម្រាប់កម្មវិធីស្ត្រីមានផ្ទៃពោះ (Presumptive Eligibility for Pregnant Women Program) ក្រដាសព័ត៌មានអ្នកជំងឺ

## តើ Presumptive Eligibility for Pregnant Women (សិទ្ធិចូលរួមសន្មត់ជាមុន សម្រាប់ស្ត្រីមានផ្ទៃពោះ) (PE4PW) គឺជាអ្វី?

PE4PW គឺជាការថែទាំសុខភាពភ្លាមៗនិងបណ្ដោះអាសន្នដែលទាក់ទងនឹងការមានផ្ទៃពោះសម្រាប់ស្ត្រីដែលមានប្រាក់ចំណូលតិចរួមទាំងការពន្លូតកូននិងការរលូតកូន។ការទៅជួបគ្រូពេទ្យគ្លីនិកនិងពេទ្យសង្គ្រោះបន្ទាន់ភាគច្រើនត្រូវបានធានារ៉ាប់រង។

វីតាមីនថែរក្សាគភ៌និងថ្នាំភាគច្រើនត្រូវបានធានារ៉ាប់រង។ PE4PW មិនបង់ធានារ៉ាប់រងការថែទាំការឈឺពោះនិងការសម្រាលកូនឬការថែទាំសម្រាកនៅមន្ទីរពេទ្យឡើយ។

អ្នកត្រូវតែដាក់ពាក្យសុំពេញលេញដើម្បីទទួលការធានារ៉ាប់រងសម្រាប់ការថែទាំការឈឺពោះនិងការសម្រាលកូន។

## តើអ្នកណាខ្លះដែលមានសិទ្ធិទទួល PE4PW?

ស្ត្រីណាក៏បានដែលគិតថាគាត់មានផ្ទៃពោះហើយដែលប្រាក់ចំណូលរបស់គ្រួសារមាននៅតិចជាងចំនួនមួយ មានសិទ្ធិទទួល PE4PW។

ស្ត្រីមានផ្ទៃពោះត្រូវបានរាប់ជាពីរនាក់ឬច្រើនជាងអាស្រ័យទៅលើថាមានកូនប៉ុន្មាននាក់នឹងកើតមក។ ការធានារ៉ាប់រង PE4PW ចាប់ផ្ដើមនៅថ្ងៃនៃការចុះឈ្មោះ។

## តើខ្ញុំអាចដាក់ពាក្យសុំ PE4PW យ៉ាងដូចម្ដេច?

អ្នកត្រូវតែដាក់ពាក្យសុំតាមរយៈអ្នកផ្ដល់សេវាដែលចូលរួមមានគុណសម្បត្តិគ្រប់គ្រាន់។សូមសួរគ្រូពេទ្យឬគ្លីនិករបស់អ្នកថាតើពួកគេផ្ដល់កម្មវិធីហ្នឹងឬទេ ឬទៅកាន់ www.dhcs.ca.gov/services/medi-cal/eligibility/Pages/PE.aspx សម្រាប់បញ្ជីអ្នកផ្ដល់សេវាមួយច្បាប់។

## តើខ្ញុំអាចទទួលការធានារ៉ាប់រងក្រោម PE4PW រយៈពេលយូរប៉ុណ្ណា?

ទាល់តែការដាក់ពាក្យសម្រាប់កម្មវិធីធានារ៉ាប់រងសុខភាពពេញលេញល្មមបង់ថ្លៃបានរួមទាំង Medi-Cal ត្រូវបានអនុម័ត ឬបដិសេធសិន។

អ្នកត្រូវតែដាក់ពាក្យសុំពេញលេញដើម្បីបន្តទទួលបានការធានារ៉ាប់រង PE ។

## តើខ្ញុំដាក់ពាក្យសុំកម្មវិធីធានារ៉ាប់រងសុខភាពល្មមបង់ថ្លៃបានរួមទាំង Medi-Cal យ៉ាងដូចម្ដេច?

- តាមអ៊ីនធឺណែត នៅ www.CoveredCA.com
- លេខទូរស័ព្ទ 1-800-300-1506
- ដោយផ្ទាល់ - ទាក់ទងមក CoveredCA តាមអ៊ីនធឺណែត ឬជាមួយលេខ 800 ដើម្បីទទួលបញ្ជីមួយនៃកន្លែងនានា
- ទីភ្នាក់ងារសេវាកម្មសង្គមខោនធី
- តាមអ៊ីនធឺណែតនៅ www.benefitscal.com សម្រាប់កម្មវិធីនានារបស់ខោនធី
- ទាញយកនិងបោះពុម្ពពាក្យសុំ CoveredCA Application មួយ នៅ www.coveredca.com/apply/

  សូមផ្ញើទូរសារទៅកាន់៖ 1-888-329-3700 ឬ

  សូមផ្ញើសំបុត្រទៅកាន់៖ Covered California
  P.O. Box 989725
  West Sacramento, CA 95798

## ការចុះឈ្មោះ Text4baby

Medi-Cal ផ្ដល់យោបល់ប្រើ Text4Baby ដែលជាសេវាកម្មឥតគិតថ្លៃ100%។ Text4baby នឹងផ្ញើការរំលឹកការណាត់ជួបគ្រូពេទ្យព័ត៌មានអំពីការថែទាំគភ៌ការលូតលាស់របស់ទារកសញ្ញានៃការឈឺពោះសម្រាលកូនការបំបៅដោះអាហារបំប៉ននិងជាច្រើនទៀតតាមរយៈទូរស័ព្ទដៃរបស់អ្នក។វាឥតគិតថ្លៃទេទោះបីជាអ្នកមិនមានការផ្ញើសារនៅក្នុងគម្រោងរបស់ទូរស័ព្ទដៃអ្នកក៏ដោយ។ ដើម្បីចុះឈ្មោះសរសេរសារទូរស័ព្ទ BABY ឬ BEBE ទៅកាន់ 511411 ឬទៅអ៊ីនធឺណែតនៅឯ www.text4baby.org។ មាន app ឥតគិតថ្លៃនៅក្នុង iTunes និងហាងលក់ GooglePlay។

## ចុះបើខ្ញុំទទួលសំបុត្រគិតលុយសម្រាប់សេវាកម្មថែទាំសុខភាពដែលខ្ញុំបានទទួល?

បើអ្នកមានសេវាកម្ម ដែលកម្មវិធី PE4PW មិនបង់ថ្លៃឲ្យនោះ Medi-Cal ប្រហែលបង់ថ្លៃឲ្យសម្រាប់សេវាកម្មទាំងនោះ។ **ដាក់ពាក្យសុំ Medi-Cal ក្នុងរវាងបីខែពីថ្ងៃខែឆ្នាំរបស់សេវាកម្មសុខភាព (មិនមែនថ្ងៃខែឆ្នាំរបស់សំបុត្រគិតលុយទេ— នោះប្រហែលជាយឺតពេកហើយ)**។ ឆ្លើយ "បាទ/ចាស់" ចំពោះសំណួរនៅលើពាក្យសុំអំពីចំណាយសុខភាពនៅក្នុងបីខែកន្លងទៅ ទោះបីជាអ្នកមិនទទួលបានទទួលសំបុត្រគិតលុយនៅឡើយក៏ដោយ។បើអ្នកមិនចង់បានការធានារ៉ាប់រងបន្ទាប់ពី PE4PW ដោយសារអ្នកមានការរលូតកូនឬដោយសារហេតុផលណាមួយផ្សេងទៀតអ្នកគួរតែនៅតែដាក់ពាក្យសុំនិងគូស "បាទ/ចាស់" សម្រាប់ការបង់ធានារ៉ាប់រងបីខែ។

## បើខ្ញុំបានបង់ការថែទាំសុខភាពរបស់ខ្ញុំរួចហើយ?

បើអ្នកដាក់ពាក្យសុំហើយទទួលបាន Medi-Cal សូមស្នើសុំឲ្យអ្នកផ្ដល់សេវារបស់អ្នកគិតលុយដល់ Medi-Cal ហើយផ្ដល់លុយដល់អ្នកវិញ។

បើអ្នកផ្ដល់សេវាមិនផ្ដល់ឲ្យវិញសូមទូរស័ព្ទឬសរសេរទៅកម្មវិធី Medi-Cal នៅក្នុងSacramento អំពី *Conlan* Beneficiary Reimbursement Program។

### សម្រាប់សំណុំរឿងគិតលុយសុខភាព៖

Department of Health Care Services
Beneficiary Services
P.O. Box 138008
Sacramento, CA 95813-8008
916-403-2007
TDD: 916-635-6491

### សម្រាប់សំណុំរឿងគិតលុយធ្មេញ៖

Denti-Cal
Beneficiary Services
P.O. Box 526026
Sacramento, CA 95852-6026
916-403-2007
TDD: 916-635-6491